CITY OF LONGBEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 13 ខែមករា ឆ្នាំ 2021

ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងភ្នំពេញ, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយ ភ្លាមៗ

## សាលាក្រុងបានដាស់តឿនសាធារណជន ឱ្យយល់ដឹង ពីព័ត៌មានក្លែងក្លាយ អំពីការចាក់ថ្នាំបង្ការ COVID-19 ។

ទីក្រុងឡុងប៊ិច, រដ្ឋ CA - ប្រជាពលរដ្ឋត្រូវបានណែនាំឱ្យយល់ដឹង ពីព័ត៌មានក្លែងក្លាយ អំពីការចាក់ថ្នាំបង្ការ COVID-19 ដែលកើតមាន នៅទូទាំងតំបន់ ហើយបុគ្គលម្នាក់ៗ ត្រូវបានជំរុញឱ្យរាយការណ៍ ពីសកម្មភាព ដែលគួរឱ្យសង្ស័យ ។ ក្នុងអំឡុងពេលឆ្លងរាលដាលវីរុសថ្មីនេះ អ្នកបង្កើត ព័ត៌មានក្លែងក្លាយ ប្រើប្រាស់ ការទូរសព្ទដោយម៉ាស៊ីន ប៉ុស្តិ៍ព័ត៌មានលើបណ្តាញសង្គម និងអ៊ីមែល ដើម្បីទាញប្រយោជន៍ ពីការភ័យខ្លាច ភាពតានតឹងចិត្ត និងការភ័ន្តច្រឡំ អំពីវីរុសនេះ ។ ជាវិធានការបង្ការជាមុន បុគ្គលម្នាក់ៗ គួរប្រយ័ត្នប្រយែង អំពីព័ត៌មានផ្ទាល់ខ្លួន របស់ពួកគេ និងឱកាសឆាប់ទទួលបានការចាក់ថ្នាំបង្ការ ដែលគួរឱ្យសង្ស័យ ។

នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស (នាយកដ្ឋានសុខាភិបាល) កំពុងចាត់ចែងដំណើរការចាក់ថ្នាំបង្ការ នៅឡុងប៊ិច ។ ការបែងចែកថ្នាំបង្ការ ត្រូវបានចាត់ចែង ទៅតាម កម្លាំងពលកម្មនៃតំបន់យុត្តាធិការសុខាភិបាល ហើយថ្នាំបង្ការត្រូវរៀបចំផ្តល់ជូនបុគ្គលម្នាក់ៗ ក្នុងពីរដំណាក់កាល ដោយមានដំណាក់កាលរង និងអាទិភាពរង រៀបជាលំដាប់ថ្នាក់ ។ ការចែកចាយថ្នាំបង្ការ COVID-19 យ៉ាងទូលំទូលាយ ជូនសាធារណជន គឺត្រៀមរៀបចំរាប់ខែជាមុន ហើយនឹងមានផ្តល់ ជូន ប្រជាពលរដ្ឋឡុងប៊ិច ដោយឥតគិតថ្លៃ ដោយមិនប្រកាន់ពីឋានៈអន្តោប្រវេសន៍ ។

មន្ទីរសុខាភិបាល និងនាយកដ្ឋាននគរបាល សូមក្រើនរំឭកប្រជាពលរដ្ឋអំពីចំណុច ដូចតទៅនេះ ៖

- និយោជិតក្រុង មិនទំនាក់ទំនងទៅ ប្រជាពលរដ្ឋជាមុន ដោយសាកសួរ អំពីព័ត៌មានអត្តសញ្ញាណ ឬព័ត៌មានផានារ៉ាប់រង នោះទេ ។ សូមកុំប្រាប់ ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ទៅប្រភព ដែលមិនស្គាល់ឱ្យសោះ ។
- ប្រសិនបើមានមនុស្សព្យាយាមលក់ឱកាសផ្លោះលំដាប់លេខរៀង ឬ ទទួលបានការចាក់ថ្នាំបង្ការ មុនពេលដល់វេនលោកអ្នកនោះ វាជាការបោកប្រាស់ទេ ។
- ប្រសិនបើមនុស្សនិយាយថា គេអាចរកថ្នាំបង្ការ ដែលមានថ្លៃទាប ឬ រកថ្នាំបង្ការក្រោមតុ ឱ្យលោកអ្នកបាន វាជាការបោកប្រាស់ទេ ។
- ប្រសិនបើមានមនុស្ស នៅតាមផ្លូវ នៅលើអ៊ីនធឺណែត បណ្តាញសង្គម ឬ ចូលមកគោះទ្វាលោកអ្នក ដើម្បីលក់ថ្នាំបង្ការនោះ សូមបដិសេធសំណើរបស់ពួកគេ ។ គ្មានជនណាម្នាក់ ដែលលក់ថ្នាំបង្ការ នៅលើអ៊ីនធឺណែត ជាការស្របច្បាប់នោះទេ ។
- ប្រសិនបើលោកអ្នកបានទាក់ទងទៅ នាយកដ្ឋានសុខាភិបាល ដើម្បីស្នើសុំការចាក់ថ្នាំបង្ការ និងការណាត់ជួប នោះពួកគេអាចដាក់ឈ្មោះលោកអ្នក នៅក្នុងបញ្ជីរង់ចាំ ប៉ុន្តែពួកគេនឹងមិនស្នើឱ្យលោកអ្នកបង់ថ្លៃនោះទេ ។

CITY OF LONG BEACH

# PRESS RELEASE

ដើម្បីស្វែងយល់បន្ថែមទៀត អំពីព័ត៌មានក្លែងក្លាយ និងការបោកប្រាស់ ជាទូទៅ ពាក់ព័ន្ធនឹង COVID-19 សូមចូលមើល គេហទំព័រ ស្តីពី COVID-19 របស់នាយកដ្ឋានសុខាភិបាល ឡុងប៊ិច និង គេហទំព័រសុខភាពសាធារណៈ ខោនធីឡូស អ៊ែនជីឡេស ។ ដើម្បីរាយការណ៍ អំពីព័ត៌មានក្លែងក្លាយ ស្តីពី COVID-19 ដែលអាចកើតមាន សូមចូលមើល គេហទំព័រ របស់នាយកដ្ឋានកិច្ចការធុរកិច្ច និងអតិថិជន ខោនធីឡូស អ៊ែនជីឡេស ឬទូរសព្ទទៅលេខ 800.593.8222 ។

បុគ្គលម្នាក់ៗ អាចរាយការណ៍ អំពីការអះអាង បែបក្លែងបន្លំ ឬ គួរឱ្យសង្ស័យ ស្តីពីថ្នាំបង្ការ ផលិតផល សម្រាប់ការធ្វើតេស្ត ឬ ការព្យាបាល ដោយទាក់ទងទៅ បេសកកម្មពាណិជ្ជកម្មសហព័ន្ធ (FTC) តាមអ៊ីនធឺណែត ។

ប្រសិនបើលោកអ្នកគិតថា មានមនុស្សកំពុងក្លែងខ្លួនជា និយោជិតសាលាក្រុងឡុងប៊ិចនោះ សូមទូរសព្ទទៅ មជ្ឈមណ្ឌលទំនាក់ទំនងពេលមានអាសន្ន របស់ក្រុង តាមរយៈលេខ 9-1-1 ឬ 562.435.6711 ។

ការសាកសួរ ពីប្រព័ន្ធផ្សព្វផ្សាយ អាចបញ្ជូនទៅ មជ្ឈមណ្ឌលទំនាក់ទំនងរួម របស់សាលាក្រុងឡុងប៊ិច តាមរយៈ 562.570.NEWS, jic@longbeach.gov ។

###